ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

## " កម្ពុជា និង អង្គការ UNICEF បន្តលើកកម្ពស់ កិច្ចសហប្រតិបត្តិការជិតស្និទ្ធថែមទៀត "

"អង្គការ UNICEF បានអះអាងអំពីការបន្តផ្តល់ការគាំទ្រ និងជំនួយរបស់ខ្លួនដល់កម្ពុជា" នេះជាការបញ្ជាក់របស់ លោក William Parks តំណាងតែងតាំងថ្មីនៃអង្គការមូលនិធិកុមាររបស់អង្គការសហប្រជាជាតិ (UNICEF) ប្រចាំកម្ពុជា នៅក្នុងឱកាសប្រគល់លិខិតសារតាំងជូន **ឯកឧត្តម អ៊ុច បូរិទ្ធ រដ្ឋមន្ត្រីស្តីទីនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣ នៅទីស្តីការក្រសួង។

**ឯកឧត្តម រដ្ឋមន្ត្រីស្តីទី** បានសម្តែងការស្វាគមន៍ និងបានអះអាងចំពោះប្រេសិតថ្មីអំពីការគាំទ្រយ៉ាងពេញទំហឹងរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះរូបលោកនិងក្រុមការងាររបស់លោក ក្នុងការបំពេញការងារដ៏សំខាន់របស់អង្គការ UNICEF នៅកម្ពុជា។ បន្ថែមទៀត **ឯកឧត្តម រដ្ឋមន្ត្រីស្តីទី** បានរំលឹកពីប្រវត្តិដ៏យូរលង់នៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងអង្គការ UNICEF ជាពិសេស ការផ្តល់ជំនួយក្រោយពីការដួលរលំរបបខ្មែរក្រហម ដែលជំនួយនេះបានរួមចំណែកបន្ធូរការលំបាកនានារបស់ប្រជាជនកម្ពុជានាពេលនោះ។ **ឯកឧត្តម** ក៏បានថ្លែងអំណរគុណចំពោះគម្រោងរបស់អង្គការ UNICEF លើវិស័យអប់រំ សុខភាពនិងអាហារូបត្ថម្ភ កិច្ចការពារកុមារ ទឹកស្អាតនិងអនាម័យ ព្រមទាំងគោលនយោបាយនិងហិរញ្ញប្បទានសាធារណៈសម្រាប់កុមារ។ កិច្ចខិតខំប្រឹងប្រែងនាពេលថ្មីៗរបស់អង្គការ UNICEF ក្នុងការជួយដល់សុខុមាលភាពកុមារ និងក្រុមគ្រួសាររបស់ពួកគេ ក្នុងអំឡុងការរាតត្បាតនៃជំងឺកូវីដ-១៩ ព្រមទាំងជំនួយក្នុងការបើកសាលារៀនឡើងវិញប្រកបដោយសុវត្ថិភាពក៏ត្រូវបានទទួលស្គាល់ផងដែរ ។

លោក William Parks មានការភ្ញាក់ផ្អើលចំពោះការវិវត្តរីកចម្រើនយ៉ាងខ្លាំងរបស់កម្ពុជានាពេលបច្ចុប្បន្ន បើប្រៀបធៀបទៅនឹងពេលដែលលោកធ្លាប់បានមកដល់កម្ពុជា នៅឆ្នាំ២០០២។ ជាមួយនឹងការកោតសរសើរពីកិច្ចសហប្រតិបត្តិការរឹងមាំរវាងកម្ពុជា និង អង្គការ UNICEF លោកក៏បានអះអាងពីការប្តេជ្ញាចិត្តក្នុងការថែរក្សាទំនាក់ទំនងនេះ ហើយនឹងបន្តធ្វើកិច្ចការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធទាំងអស់លើវិស័យដែលបានគូសបញ្ជាក់ខាងលើ។

ជាទីបញ្ចប់ ភាគីទាំងពីរបានអះអាងជាថ្មីម្តងទៀតអំពីការប្តេជ្ញាចិត្តរួមគ្នា ក្នុងការបន្តពង្រឹងកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងកម្ពុជា និងអង្គការ UNICEF៕

ថ្ងៃអង្គារ ៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស .២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២៣

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh